ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# របាយការណ៍
# ស្ដីពី
# ការវិភាគទិន្នន័យអធិការកិច្ច
# កន្លែងថែទាំកុមារនៅកម្ពុជា
# ២០១៩-២០២៤


រៀបចំដោយ
នាយកដ្ឋានកិច្ចការពារកុមារ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ឆ្នាំ២០២៥


Provided by the
United States of America

unicef
ដើម្បីកុមារគ្រប់រូប

# មាតិកា


**អារម្ភកថា** ..... ii

**សេចក្តីផ្តើម** ..... iv

**និយមន័យ** ..... vi

**ផ្នែកទី ១៖ ស្ថានភាពនៃកន្លែងថែទាំកុមារ** ..... ១

**របកគំហើញសំខាន់ៗ** ..... ១

១.១ ចំនួនកន្លែងថែទាំកុមារ ..... ១

១.២ ការគ្រប់គ្រង និងប្រភពថវិកា ..... ៣

១.៣ ការអនុវត្តបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ ..... ៥

១.៤ ការចុះបញ្ជី ..... ៧

១.៥ ការផ្តល់លិខិតអនុញ្ញាត ..... ៨

១.៦ ចំនួនអង្គការដៃគូថែទាំតាមសហគមន៍ដែលមានអនុស្សរណៈនៃការយោគយល់គ្នា (MOU) ..... ៨

១.៧ ផែនការអនាគត ..... ៩

**ផ្នែកទី ២៖ ស្ថានភាពកុមារដែលកំពុងរស់នៅក្នុងកន្លែងថែទាំកុមារ** ..... ១១

**របកគំហើញសំខាន់ៗ** ..... ១១

២.១ ចំនួនកុមាររស់នៅក្នុងកន្លែងថែទាំកុមារ ..... ១២

២.២ ចំនួនយុវជន (អាយុពី១៨ឆ្នាំឡើង) រស់នៅក្នុងកន្លែងថែទាំកុមារ ..... ១៣

២.៣ កុមារមានពិការភាព ..... ១៤

២.៤ ស្ថានភាពឪពុកម្តាយរបស់កុមាររស់នៅក្នុងកន្លែងថែទាំ ..... ១៥

២.៥ កម្រិតនៃការអប់រំ ..... ១៦

២.៦ ការបញ្ជូនកុមារមកថែទាំក្នុងកន្លែងថែទាំកុមារ ..... ១៧

២.៧ កុមាររស់នៅក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ ..... ១៨

**ផ្នែកទី ៣៖ អនុសាសន៍** ..... ២២

**អនុសាសន៍** ..... ២២

**ឧបសម្ព័ន្ធ៖ ទិន្នន័យតាមខេត្ត** ..... ២៥

# អារម្ភកថា

ការថែទាំជំនួស គឺជាផ្នែកមួយដ៏សំខាន់នៃការផ្តល់សេវាចំពោះកុមាររងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទ។ ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពនៃការថែទាំជំនួសចំពោះកុមារ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០០៦។ដើម្បីអនុវត្តគោលនយោបាយនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ.) បានរៀបចំបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅក្នុងមណ្ឌលឆ្នាំ២០០៦ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ឆ្នាំ២០០៨ និងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០១១។ តាមរយៈការអនុវត្តគោលនយោបាយ បទដ្ឋានអប្បបរមា និងប្រកាសនីតិវិធីខាងលើនេះ អស់រយៈពេលជាង១០ឆ្នាំមក ក្រសួង ស.អ.យ. បានកែសម្រួលគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឡើងវិញ និងដាក់ឱ្យអនុវត្តប្រកាសលេខ ១០០ ស.អ.យ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤ និងទទួលបានសារលិខិតគាំទ្រពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៤ ដើម្បីគាំទ្រ និងណែនាំជំរុញការអនុវត្តគោលនយោបាយនេះឱ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផល។ គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៤នេះ ត្រូវបានកែសម្រួលឡើងវិញឱ្យស្របតាមកម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នៃរដ្ឋសភានីតិកាលទី៧ និងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិសម្រាប់ការថែទាំជំនួសចំពោះកុមារឆ្នាំ២០០៩។

ជាមួយគ្នានេះ ស្របតាមកម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ការងារថែទាំជំនួសនៅកម្ពុជាត្រូវបានកែទម្រង់ តាមរយៈការដាក់ចេញនូវអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ និងអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារ "ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ" ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ការប្រគល់មុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារ "ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍" ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ។

ផ្អែកតាមការកែទម្រង់ការងារថែទាំជំនួសខាងលើ ក្រសួង ស.អ.យ. បានបង្កើតឱ្យមាននីតិវិធី និងទម្រង់សម្រាប់ធ្វើអធិការកិច្ចកន្លែងថែទាំជំនួសចំពោះកុមារ និងបានប្រែក្លាយពីការប្រើប្រាស់ដោយក្រដាស ទៅជាប្រព័ន្ធបច្ចេកវិទ្យា និងជាប្រព័ន្ធទិន្នន័យអធិការកិច្ចដែលមានភាពងាយស្រួល សុវត្ថិភាព និងរក្សាការសម្ងាត់។ ទន្ទឹមនឹងនេះការកសាង និងពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចនៅថ្នាក់ក្រសួង មន្ទីរ ស.អ.យ រាជធានី ខេត្ត និងរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ត្រូវបានធ្វើជាប្រចាំ តាមរយៈការបណ្តុះបណ្តាល និងការផ្តល់បច្ចេកទេសដោយផ្ទាល់ សំដៅធានាប្រសិទ្ធភាពនៃការធ្វើអធិការកិច្ចកន្លែងថែទាំកុមារទូទាំងប្រទេស។

ក្នុងនាមក្រសួង ស.អ.យ ខ្ញុំសូមកោតសរសើរដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនាយកដ្ឋានកិច្ចការពារកុមារ នៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត អង្គការយូនីសេហ្វ អង្គការមិនមែនរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ ដែល

បានខិតខំចូលរួមក្នុងការរៀបចំរបាយការណ៍ស្ដីពីការវិភាគទិន្នន័យអធិការកិច្ចកន្លែងថែទាំកុមារនៅកម្ពុជា ឆ្នាំ ២០១៥-២០២៤នេះ។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា គ្រប់ភាគីពាក់ព័ន្ធទាំងអស់នឹងប្រែក្លាយព័ត៌មានសំខាន់ៗដែលមាននៅក្នុងរបាយការណ៍នេះ ទៅជាសកម្មភាពអនុវត្តជាក់ស្ដែង ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្ដល់សេវាថែទាំជំនួស សំដៅធានាបាននូវកិច្ចការពារ និងឧត្តមប្រយោជន៍ពេញលេញសម្រាប់កុមារកម្ពុជា។

ថ្ងៃច័ន្ទ ២រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥

រដ្ឋមន្ត្រី

ជា សុមេធី

# សេចក្តីផ្តើម

កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ តុលា ឆ្នាំ១៩៩២ ហើយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៨ ក៏បានចែងថា រដ្ឋធានាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលការអភិវឌ្ឍ សិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួម។ រដ្ឋការពារប្រឆាំងនឹងការងារទាំងឡាយណាដែលអាធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។ ជាមួយគ្នានេះ ដើម្បីឧត្តមប្រយោជន៍របស់កុមារ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា និងពិធីសារបន្ថែមអន្តរជាតិពាក់ព័ន្ធដទៃទៀត រួមមាន អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឆ្នាំ២០០៥ អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៣៨ ស្តីពីការកំណត់អាយុអប្បបរមាសម្រាប់ការចូលធ្វើការងារឆ្នាំ១៩៩៩ អនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសឆ្នាំ២០០៧ អនុសញ្ញាស្តីពីសិទ្ធិជនពិការឆ្នាំ២០១២ ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ឆ្នាំ២០០៦ ពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារនិងស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ ឆ្នាំ២០០២។

ក្នុងនាមជាប្រទេសហត្ថលេខីនៃអនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិ ដើម្បីកិច្ចការពារកុមារ លើកកម្ពស់ប្រសិទ្ធភាព និងគុណភាពការថែទាំជំនួសចំពោះកុមារ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ ដើម្បីអនុវត្តគោលនយោបាយនេះ ក្រសួងបានរៀបចំបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌលឆ្នាំ២០០៦ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ឆ្នាំ២០០៨ និងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០១១ ។ ទន្ទឹមនេះរាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យលេខលេខ៩០ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែស្រួលមាត្រា៧ នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលរបស់រដ្ឋ អនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ និងអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារ "ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ"ទៅឱ្យរដ្ឋបាល រាជធានី ខេត្ត ការប្រគល់មុខងារ "ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការប្រគល់មុខងារ "ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងសហគមន៍" ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត។

នៅឆ្នាំ២០១៥ ក្រសួង ស.អ.យ សហការជាមួយអង្គការយូនីសេហ្វ បានចុះស្រាវជ្រាវធ្វើការកំណត់ទីតាំង កន្លែងថែទាំកុមារ បានរកឃើញកន្លែងថែទាំកុមារចំនួន ៦៣៩កន្លែង ដែលមានកុមារ និងយុវជនវ័យក្មេងសរុបចំនួន ៣៥.៣៧៤នាក់ (ស្រី៤៥%) ក្នុងនោះ ២៦.១៨៧នាក់ មានអាយុក្រោម១៨ឆ្នាំ (កុមារី ៤៨%)

និងយុវជនវ័យក្មេងចំនួន ៩.១៨៧នាក់។ តាមរយៈការសិក្សានេះ នៅឆ្នាំ២០១៦ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចាត់វិធានការអាទិភាពសំដៅកែទម្រង់ការថែទាំជំនួសនៅកម្ពុជា រួមមាន ការដាក់ឱ្យអនុវត្ត "ផែនការពង្រឹងការថែទាំកុមារ និងសមាហរណកម្មកុមារចំនួន ៣០ភាគរយ ពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាព" ពីឆ្នាំ២០១៦ ការរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានអធិការកិច្ចឌីជីថល ដើម្បីគ្រប់គ្រងទិន្នន័យ និងរាយការណ៍អំពីការធ្វើអធិការកិច្ចប្រចាំឆ្នាំទៅលើកន្លែងថែទាំកុមារទាំងអស់នៅទូទាំងប្រទេស និងការពិនិត្យតាមដានវឌ្ឍនភាពនៃផែនការសកម្មភាពសម្រាប់ការពង្រឹងការថែទាំកុមារ។ បន្ថែមលើនេះ នៅឆ្នាំ២០២៣ ក្រសួងបានបន្តរៀបចំនិងដាក់ឱ្យអនុវត្តផែនការសកម្មភាពស្តីពីការពង្រឹងការថែទាំជំនួសចំពោះកុមារ២០២៣-២០២៧ និងបានកែសម្រួលឡើងវិញនូវគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឡើងវិញ និងដាក់ឱ្យអនុវត្តតាមរយៈប្រកាសលេខ ១០០ ស.អ.យ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤ ដែលការកែសម្រួលឡើងវិញនេះគឺដើម្បីឱ្យស្របតាមកម្មវិធី គោលនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាលទី១ នៃរដ្ឋសភា អាណិត្តទី៧ និងគោលការណ៍ណែនាំអង្គការសហប្រជាជាតិសម្រាប់ការថែទាំជំនួសចំពោះកុមារឆ្នាំ២០០៩។ បច្ចុប្បន្ន ក្រសួងបាននិងកំពុងរៀបចំកែសម្រួលឡើងវិញនូវបទដ្ឋានអប្បបរមាសម្រាប់ ការថែទាំជំនួសចំពោះកុមារ ដើម្បីឱ្យស្របជាមួយនឹងគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០២៤។

ចាប់តាំងការអនុវត្តសកម្មភាពអាទិភាពខាងលើ នេះជាលើកដំបូងនៃការរៀបចំរបាយការណ៍ដែលមានលក្ខណៈវិភាគស្ថានភាព និងនិន្នាការនៅក្នុងកន្លែងថែទាំកុមារនៅទូទាំង ២៥រាជធានី ខេត្ត នៃប្រទេសកម្ពុជា ព្រមទាំងកុមារដែលកំពុងរស់នៅក្នុងកន្លែងថែទាំទាំងអស់ ចាប់ពីឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០២៤។ របាយការណ៍នេះផ្តល់ព័ត៌មានសំខាន់ៗ សម្រាប់ពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពស្តីពីការពង្រឹងការថែទាំកុមារ គោលនយោបាយ និងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារ រួមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។ របាយការណ៍នេះបែងចែកជាបីផ្នែក៖ បន្ទាប់ពីសេចក្តីផ្តើម ផ្នែកទី១ បង្ហាញអំពីស្ថានភាពនៃកន្លែងថែទាំកុមារ ផ្នែកទី២ ពិនិត្យមើលស្ថានភាពរបស់កុមារដែលកំពុងរស់នៅក្នុងកន្លែងថែទាំកុមារ ផ្នែកទី៣ ផ្តល់អនុសាសន៍ និងផ្នែកចុងក្រោយជាឧបសម្ព័ន្ធដែលបង្ហាញទិន្នន័យទៅតាមរាជធានីខេត្ត និងឆ្នាំ។

របាយការណ៍នេះប្រើប្រាស់ប្រភពទិន្នន័យពីរបាយការណ៍ ស្តីពីការកំណត់ទីតាំងកន្លែងថែទាំកុមារនៅឆ្នាំ២០១៥ និងទិន្នន័យអធិការកិច្ចប្រចាំឆ្នាំពីប្រព័ន្ធគ្រប់គ្រងព័ត៌មានអធិការកិច្ចឌីជីថលរបស់ក្រសួងពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៤។ ការសម្អាត និងការផ្ទៀងផ្ទាត់ទិន្នន័យត្រូវបានរៀបចំឡើង ដើម្បីធានាភាពត្រឹមត្រូវនៅមុនពេលនៃការរៀបចំការវិភាគនេះ។ ការរៀបចំរបាយការណ៍នេះត្រូវបានធ្វើឡើងដោយមានការគាំទ្របច្ចេកទេសពីអង្គការយូនីសេហ្វ ដោយពិគ្រោះយោបល់ជាមួយមន្ត្រីជំនាញនាយកដ្ឋានកិច្ចការពារកុមារនៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ដោយសារទិន្នន័យទាំងនេះ មានលក្ខណៈជាទិន្នន័យបែបបរិមាណច្រើន ដូចនេះបរិបទនៃការវិភាគក្នុងរបាយការណ៍នេះនៅមានកម្រិតនៅឡើយ។

# និយមន័យ

**កន្លែងថែទាំកុមារ (RCF)** សំដៅដល់ការថែទាំកុមារមានលក្ខណៈមិនមែនជាគ្រួសារ ដែលមានបុគ្គលិកទទួលបានប្រាក់បៀវត្សរ៍ កុមារទទួលបានសេវា និងរស់នៅក្នុងកន្លែងថែទាំ ព្រមទាំងស្នាក់នៅទាំងពេលយប់ទាំងពេលថ្ងៃ។ កន្លែងថែទាំកុមារដែលត្រូវបានធ្វើអធិការកិច្ចកន្លងមក រួមមាន មណ្ឌលថែទាំកុមារ វត្តអារាម ឬកន្លែងសាសនាដទៃទៀត អន្តេវាសិកដ្ឋាន ផ្ទះស្នាក់នៅជាក្រុម ផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់។

**មណ្ឌលថែទាំកុមារ (RCI)** សំដៅដល់មណ្ឌលសម្រាប់ការស្នាក់នៅដែលផ្តល់អ្វីៗទៅតាមតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍន៍របស់កុមារ ដែលបានបាត់បង់ឪពុក ឬម្តាយ ឬបាត់បង់ទាំងឪពុកម្តាយបង្កើត។ ជាការពិតមណ្ឌលទាំងនេះក៏ទទួលយកផងដែរនូវកុមារដែលប្រឈមមុខនឹងគ្រោះថ្នាក់ ឬត្រូវការកិច្ចការពារពិសេស ប៉ុន្តែមណ្ឌលទាំងនេះពុំអាចផ្តល់សេវាពិសេសបានទេ[1]។

**វត្តអារាម និងកន្លែងសាសនាដទៃទៀត** សំដៅដល់ការថែទាំដែលផ្តល់ជូនកុមារដោយព្រះសង្ឃ ដូនជី អាចារ្យ និងស្ថាប័នសាសនា ដែលជួយដោះស្រាយសេចក្តីត្រូវការមូលដ្ឋានរបស់កុមារនៅក្នុងវត្ត និងទីកន្លែងជំនឿសាសនាដទៃទៀត។

**អន្តេវាសិកដ្ឋាន** សំដៅដល់ការរៀបចំលំនៅដ្ឋានសម្រាប់កុមារស្នាក់នៅរយៈពេលសិក្សាមួយវគ្គ ឬច្រើនវគ្គ ដើម្បីទទួលបានការអប់រំនៅឆ្ងាយពីផ្ទះ។

**ផ្ទះស្នាក់នៅជាក្រុម** សំដៅដល់ទម្រង់មួយនៃការថែទាំជំនួសនៅសហគមន៍ដែលកុមារតិចជាង៦នាក់ត្រូវបានដាក់ឱ្យរស់នៅក្នុងបរិយាកាសគ្រួសារនៅក្រោមការគ្រប់គ្រង និងការថែទាំរបស់ក្រុមអ្នកថែទាំមួយចំនួនតូច ដែលមិនមែនជាញាតិរបស់កុមារ។ ផ្ទះស្នាក់នៅជាក្រុមតូចៗស្ថិតនៅក្នុងសហគមន៍ ប៉ុន្តែមិនមែនដំណើរការដោយសហគមន៍ឡើយ។

**ផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់** សំដៅដល់ទម្រង់មួយនៃការថែទាំតាមកន្លែងថែទាំ ដែលមានកំណត់រយៈពេលស្នាក់នៅសម្រាប់កុមារ នៅក្នុងដំណើរការរៀបចំផែនការអចិន្ត្រៃយ៍គ្រួសារ ឬកុមារដែលគ្រួសារកំពុងជួបប្រទះវិបត្តិធ្ងន់ធ្ងរ និងត្រូវការស្នាក់នៅបណ្តោះអាសន្ន ដើម្បីឱ្យបរិយាកាសគ្រួសារមានស្ថិរភាពឡើងវិញ។

1 គោលនយោបាយថែទាំជំនួសចំពោះកុមារឆ្នាំ២០២៤

# ផ្នែកទី១៖ ស្ថានភាពនៃកន្លែងថែទាំកុមារ

## របកគំហើញសំខាន់ៗ

- **កន្លែងថែទាំកុមារ៖** ភាគរយនៃកន្លែងថែទាំកុមារ បានធ្លាក់ចុះចំនួន ៦១% (៣៨៧កន្លែង) គឺពីចំនួន ៦៣៩កន្លែង នៅឆ្នាំ២០១៥ មកត្រឹម ចំនួន ២៥២កន្លែង នៅឆ្នាំ២០២៤។ ភាគរយនៃមណ្ឌលថែទាំកុមារបានធ្លាក់ចុះចំនួន៥៩% (២៤១កន្លែង) ពីចំនួន ៤០៦កន្លែង នៅឆ្នាំ២០១៥ មកចំនួន ១៦៥កន្លែង នៅឆ្នាំ២០២៤។ នៅឆ្នាំ២០២៤ មណ្ឌលរដ្ឋមានចំនួន ២១មណ្ឌល និងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាលចំនួន ១៤៤មណ្ឌល វត្តអារាម និងកន្លែងសាសនាចំនួន ៣៦កន្លែង អន្តេវាសិកដ្ឋានចំនួន ២៤កន្លែង ផ្ទះស្នាក់នៅជាក្រុមចំនួន ២២កន្លែង និងស្នាក់នៅបណ្ដោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់ចំនួន ៥កន្លែង។
- **កន្លែងថែទាំកុមារដែលដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល៖** នៅឆ្នាំ២០២៤ ៩២% នៃកន្លែងថែទាំកុមារ (២៣១កន្លែង) ត្រូវបានដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ព្រមទាំងទទួលបានថវិកាពីបរទេស។ ក្នុងចំណោមកន្លែងថែទាំកុមារទាំងអស់ មានកន្លែងថែទាំកុមារជាមណ្ឌលថែទាំចំនួន ២១កន្លែង គ្រប់គ្រងដំណើរការដោយរាជរដ្ឋាភិបាល។
- **បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ៖** នៅឆ្នាំ២០២៤ ៥២% នៃកន្លែងថែទាំកុមារ (១៣១កន្លែង) បានអនុវត្តស្របទៅតាមបទដ្ឋាន ប៉ុន្តែ ៤៨% (១២១កន្លែង) មិនបានអនុវត្តស្របទៅតាមបទដ្ឋានឡើយ និងស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ។ ៦២%នៃមណ្ឌលរដ្ឋ ក៏ដូចជា៦២%នៃមណ្ឌលអង្គការមិនមែនរដ្ឋាភិបាលបានអនុវត្តស្របតាមបទដ្ឋាន ប៉ុន្តែ៣៨% នៃមណ្ឌលទាំងពីរប្រភេទស្ថិតនេះនៅក្រោមបទដ្ឋានអប្បបរមា។ ភាគច្រើននៃកន្លែងថែទាំតាមសហគមន៍ នៅអនុវត្តក្រោមបទដ្ឋាន ជាពិសេសកន្លែងសាសនា។
- **ស្ថានភាពចុះបញ្ជី៖** នៅឆ្នាំ២០២៤ ប្រហែល ១៨% នៃសមាគម អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាថែទាំ (៤៥កន្លែង) មិនបានចុះបញ្ជីជាមួយក្រសួងណាមួយឡើយ ហើយនិន្នាការនេះមិនសូវប្រែប្រួលឡើយចាប់តាំងពីឆ្នាំ២០១៩មក។
- **លិខិតអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** នៅឆ្នាំ២០២៤ ៤៥% នៃមណ្ឌលថែទាំអង្គការមិនមែនរដ្ឋាភិបាល (៦៥មណ្ឌល) បានទទួលលិខិតអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំណែកឯមណ្ឌលថែទាំកុមារអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៥៤% (៧៨មណ្ឌល) ពុំមានលិខិតអនុញ្ញាត។
- **ផែនការអនាគត៖** ៥០% នៃកន្លែងថែទាំកុមារ នឹងបន្តផ្តល់សេវាសមាហរណកម្មជូនដល់កុមារនៅឆ្នាំ២០២៥ និងឆ្នាំក្រោយៗទៀត។ កន្លែងថែទាំកុមារចំនួនពីរកន្លែងនឹងធ្វើការបង្វែរ និងកន្លែងថែទាំកុមារចំនួនមួយនឹងត្រូវបិទ។

## ១.១ ចំនួនកន្លែងថែទាំកុមារ

ក្រោយពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ រដ្ឋាភិបាលកម្ពុជា បានបង្កើតមណ្ឌលកុមារកំព្រាមួយចំនួន ដើម្បីទទួលយកកុមារដែលបានបាត់បង់ឪពុកម្តាយ និងសាច់ញាតិដោយសារអង្គការខ្មែរក្រហមសម្លាប់។ ចាប់ពីឆ្នាំ១៩៩៣ ក្រៅពីមណ្ឌលថែទាំកុមាររបស់រដ្ឋ អង្គការមិនមែនរដ្ឋាភិបាលបានបង្កើតមណ្ឌលថែទាំកុមារ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការទទួលយកកុមារកំព្រា និងកុមាររងគ្រោះមកចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងបានបង្កើតកម្មវិធីថែទាំកុមារនៅតាមសហគមន៍។

តាមទិន្នន័យចុះបញ្ជីផ្លូវការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មណ្ឌលថែទាំកុមារបាន កើនឡើងពីចំនួន ១៥៤ ក្នុងឆ្នាំ២០០៥ រហូតដល់ចំនួន ២៥៤ ក្នុងឆ្នាំ២០១៥ ។

នៅឆ្នាំ២០១៥ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានធ្វើការកំណត់ទីតាំងកន្លែងថែទាំកុមារ ទាំងអស់នៅក្នុងរាជធានី-ខេត្តទាំង២៥។ ការកំណត់ទីតាំងនេះបានបង្ហាញថា ប្រទេសកម្ពុជាមានកន្លែងថែទាំកុមារ ចំនួន ៦៣៩កន្លែង រួមមាន មណ្ឌលថែទាំកុមារ (RCIs) ចំនួន ៤០៦កន្លែង (មណ្ឌលរដ្ឋចំនួន ២០កន្លែង និងមណ្ឌល អង្គការមិនមែនរដ្ឋាភិបាលចំនួន ៣៨៦កន្លែង) វត្តអារាម និងកន្លែងសាសនាដទៃទៀតដែលផ្តល់ការថែទាំចំនួន ៦៥កន្លែង អន្តេវាសិកដ្ឋានចំនួន ៧២កន្លែង ផ្ទះស្នាក់នៅជាក្រុមចំនួន ៧១កន្លែង ព្រមទាំងផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្នចំនួន ២៥កន្លែង។ ការកំណត់ទីតាំងនេះបានផ្តោតជាចម្បងទៅលើមណ្ឌល ថែទាំកុមារ ហេតុនេះការកំណត់ទីតាំងកន្លែងថែទាំប្រភេទដទៃទៀតនៅក្នុងប្រទេស នៅមានកម្រិតនៅឡើយ។

ដោយផ្អែកលើរបកគំហើញថ្មីៗពីការធ្វើអធិការកិច្ចចាប់ពីខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២៤ រូបភាព ១.១ បាន បង្ហាញថា ចំនួនកន្លែងថែទាំដែលផ្តល់ការថែទាំជូនដល់កុមារនៅទូទាំងប្រទេសកម្ពុជា បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ នៅក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ។ នៅឆ្នាំ២០១៥ កន្លែងថែទាំកុមារមានចំនួន ៦៣៩កន្លែង ធៀបនឹង ២៥២កន្លែង នៅឆ្នាំ២០២៤ ដែលបានបង្ហាញថាកន្លែងថែទាំកុមារបានធ្លាក់ចុះចំនួន ៣៨៧កន្លែង ស្មើនឹង៦១%។

រូបភាព ១.១ ចំនួនកន្លែងថែទាំកុមារ បែងចែកទៅតាមឆ្នាំ




រូបភាព១.២ បង្ហាញអំពីនិន្នាការដែលស្រដៀងគ្នានៃការធ្លាក់ចុះនៃកន្លែងថែទាំគ្រប់ប្រភេទ។ ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០២៥ ចំនួនមណ្ឌលថែទាំកុមារបានធ្លាក់ចុះពី ៤០៦ មកនៅ ១៦៥ (៥៩%)។ ក្នុងនោះមានមណ្ឌលរដ្ឋបាន កើនឡើងពីចំនួន ២០កន្លែង ទៅចំនួន ២១កន្លែង និងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាលបានថយចុះពីចំនួន ៣៨៦កន្លែង មកត្រឹមចំនួន ១៤៤កន្លែង (៦៣%)។ វត្តអារាម និងកន្លែងសាសនាដទៃទៀតបានធ្លាក់ពីចំនួន ៦៥កន្លែង មកនៅចំនួន ៣៦កន្លែង (៤៥%)[2] អន្តេវាសិកដ្ឋានបានធ្លាក់ពីចំនួន ៧២កន្លែង មកនៅចំនួន ២៤កន្លែង (៦៧%) ផ្ទះស្នាក់នៅជាក្រុម បានធ្លាក់ពីចំនួន ៧១កន្លែង មកនៅចំនួន ២២កន្លែង (៦៩%) ហើយផ្ទះស្នាក់នៅបណ្តោះអាសន្ន និងកន្លែងស្នាក់នៅ បន្ទាន់បណ្តោះអាសន្នបានធ្លាក់ពីចំនួន ២៥កន្លែង មកនៅចំនួន ៥កន្លែង (៨០%)។

2 សម្រាប់ការធ្វើអធិការកិច្ច កន្លែងថែទាំតាមវត្តអារាម និងកន្លែងសាសនាដទៃទៀត កន្លងទៅ គឺផ្តោតទៅលើកន្លែងសាសនាផ្សេងៗដែលផ្តល់ ការថែទាំកុមារតែប៉ុណ្ណោះ ដោយមិនទាន់បញ្ចូលវត្តអារាមនៅឡើយ។

រូបភាព ១.២ ចំនួនកន្លែងថែទាំកុមារ បែងចែកទៅតាមប្រភេទ




**មូលហេតុចម្បងៗនៃការធ្លាក់ចុះនូវចំនួនកន្លែងថែទាំកុមារ រួមមាន៖**

១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអនុវត្តកម្មវិធីកំណែទម្រង់ការថែទាំជំនួសចំពោះកុមារដោយពង្រឹងគុណភាពសេវាថែទាំជំនួស (អនុក្រឹត្យលេខ១១៩ អនក្រ.បក ស្ដីពីការគ្រប់គ្រងមណ្ឌលថែទាំ) ការលើកកម្ពស់ការថែទាំកុមារនៅតាមគ្រួសារ និងការសមាហរណកម្មកុមារ។

២. ការទប់ស្កាត់ការបើកមណ្ឌលថ្មីៗដោយមិនចាំបាច់។

៣. ការរីករាលដាលនៃជំងឺកូវីដ១៩ និងវិបត្តិសកល ដែលធ្វើឱ្យអង្គការ សមាគមមួយចំនួនមិនអាចស្វែងរកហិរញ្ញវត្ថុក្នុងការបន្តផ្ដល់សេវាថែទាំកុមារនៅតាមមណ្ឌលថែទាំជំនួសបានបន្តទៀត ដែលពួកគេឈានទៅសម្រេចចិត្តបិទមណ្ឌល។

៤. មណ្ឌលមួយចំនួនបានបង្វែរកម្មវិធីរបស់ខ្លួន ទៅជាផ្ទះជាក្រុម ឬផ្ទះស្នាក់នៅបណ្ដោះអាសន្ន និងការថែទាំនៅតាមគ្រួសារ (គ្រួសារសាច់ញាតិនិង គ្រួសារធម៌) ស្របតាមកម្មវិធីកំណែទម្រង់ និងការកាត់បន្ថយចំនួនមណ្ឌលថែទាំកុមាររបស់រាជរដ្ឋាភិបាល។

## ១.២ ការគ្រប់គ្រង និងប្រភពថវិកា

នៅឆ្នាំ២០២៤ ជិតពាក់កណ្ដាលនៃកន្លែងថែទាំកុមារទាំង ២៥២កន្លែង (៤៥%) បានផ្ដល់ការថែទាំកុមាររយៈពេលវែង ដែលលើសពីប្រាំមួយខែ ស្របពេលដែលកន្លែងថែទាំកុមារមួយចំនួនតូច (២%) បានផ្ដល់ការថែទាំរយៈពេលខ្លី (រូបភាព ១.៣)។ បន្ថែមលើនេះ ជិតពីរភាគបី ជាកន្លែងថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ចំណែកឯមួយភាគបីស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស។ មណ្ឌលថែទាំកុមារចំនួន ២១កន្លែង ដំណើរការដោយរាជរដ្ឋាភិបាល ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាល រាជធានី ខេត្ត ចំនួន ២០កន្លែង និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ០១កន្លែង (រូបភាព ១.៤)។ ពាក់ព័ន្ធនឹងម្ចាស់ជំនួយ កន្លែងថែទាំកុមារភាគច្រើន បានទទួលប្រភពថវិកាពីអង្គការមិនមែនរដ្ឋាភិបាល បរទេស (៩៣កន្លែង ឬ ៣៧%) និងសប្បុរសជននានាទាំងក្នុងស្រុក និងបរទេស (៥៨កន្លែង ឬ ២៣%) (រូបភាព ១.៥)។

រូបភាព ១.៣ ចំនួនកន្លែងថែទាំកុមារ បែងចែកទៅតាមប្រភេទសេវា ឆ្នាំ២០២៤




រូបភាព ១.៤ ចំនួនកន្លែងថែទាំកុមារ បែងចែកទៅតាមម្ចាស់កម្មសិទ្ធិ ឆ្នាំ២០២៤




រូបភាព ១.៥ ចំនួនកន្លែងថែទាំកុមារ បែងចែកទៅតាមប្រភពថវិកា ឆ្នាំ២០២៤



## ១.៣ ការអនុវត្តបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ

ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៤ ចំនួនកន្លែងថែទាំកុមារ ដែលអនុវត្តស្របតាមបទដ្ឋានអប្បបរមា[3] បានកើនឡើងចំនួន ២៥កន្លែង (២២%) ស្របពេលដែលកន្លែងថែទាំកុមារដែលមិនបានអនុវត្តស្របតាមបទដ្ឋាន ទាំងនេះបានធ្លាក់ចុះចំនួន ២៧កន្លែង (២១%) និងកន្លែងថែទាំកុមារដែលស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរបានធ្លាក់ ចុះចំនួន ៩៧កន្លែង (២៧%)។ ទោះជាលទ្ធផលទាំងនេះបង្ហាញវឌ្ឍនភាពប្រសើរខ្លះៗនៅក្នុងការអនុវត្តបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារនៅក្នុងកន្លែងថែទាំកុមារក្តី កន្លែងថែទាំកុមារជិតពាក់កណ្តាល (១២១កន្លែង) នៅតែត្រូវការការកែលម្អជាច្រើនបន្ថែមទៀត ដើម្បីឱ្យកុមារបានទទួលការថែទាំប្រកបដោយគុណភាព (រូបភាព ១.៦)។

រូបភាព ១.៦ ចំនួនកន្លែងថែទាំកុមារ បែងចែកទៅតាមបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ និងឆ្នាំ




ទាក់ទងនឹងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ រាជរដ្ឋាភិបាលបានកំណត់នូវបទដ្ឋានពីរប្រភេទសម្រាប់ដាក់ចេញឱ្យអនុវត្ត។ បទដ្ឋានទីមួយ សំដៅដល់ប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌលនៅឆ្នាំ២០០៦។ បទដ្ឋានទីពីរ គឺប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងសហគមន៍នៅឆ្នាំ២០០៨ ដើម្បីធ្វើអធិការកិច្ចការថែទាំកុមារនៅតាមសហគមន៍ ដែលរួមមាន ការថែទាំកុមារតាមវត្តអារាម និងកន្លែងសាសនាដទៃទៀត អន្តេវាសិកដ្ឋាន ផ្ទះស្នាក់នៅជាក្រុម និងផ្ទះស្នាក់នៅបណ្តោះអាសន្ន/កន្លែងស្នាក់នៅបណ្តោះអាសន្ន។

---

3 ការធ្វើអធិការកិច្ចកន្លែងថែទាំកុមារគ្រប់ប្រភេទ ពាក់ព័ន្ធនឹងការអនុវត្តបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ បានទើបតែចាប់ផ្តើមឡើងនៅក្នុងឆ្នាំ២០១៩ ប៉ុណ្ណោះ ហើយការធ្វើអធិការកិច្ចចុងក្រោយគឺនៅចុងឆ្នាំ២០២៤ ហេតុនេះ ទិន្នន័យដែលត្រូវបានប្រើប្រាស់សម្រាប់ការវិភាគ នេះ គឺមានចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៤។ នៅឆ្នាំ២០២០ និងឆ្នាំ២០២១ មិនមានការធ្វើអធិការកិច្ចទេ ដោយសារការរាតត្បាតនៃជំងឺកូវីដ ១៩។

ពាក់ព័ន្ធនឹងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ បទដ្ឋានទាំងនេះមានពីរប្រភេទ។ បទដ្ឋានទីមួយ គឺប្រកាសស្តីពី បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌលនៅឆ្នាំ២០០៦ ដើម្បីធ្វើអធិការកិច្ចមណ្ឌលថែទាំកុមារ ទៅលើទិដ្ឋភាពចំនួន ៧៖ ស្បៀងអាហារ សុខភាព ការកម្សាន្ត ការអប់រំ សេរីភាព បរិក្ខារ និងការគ្រប់គ្រង។ បទដ្ឋានទីពីរ គឺប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងសហគមន៍នៅឆ្នាំ២០០៨ ដើម្បីធ្វើអធិការកិច្ចការថែទាំកុមារនៅតាមសហគមន៍ ដែលរួមមាន ការថែទាំកុមារតាមវត្តអារាម និងកន្លែងសាសនាដទៃទៀត អន្តេវាសិកដ្ឋាន ផ្ទះស្នាក់នៅជាក្រុម និងផ្ទះស្នាក់នៅបណ្តោះអាសន្ន/កន្លែងស្នាក់នៅបណ្តោះអាសន្ន ទៅលើទិដ្ឋភាពចំនួន ៩៖ ស្បៀងអាហារ អនាម័យ សុខភាព ការចូលរួម ការគ្រប់គ្រង ការបណ្តុះបណ្តាល បណ្តឹង ការអប់រំ ការដាក់វិន័យ។ ពិន្ទុសរុបនៃអធិការកិច្ចបទដ្ឋានអប្បបរមាត្រូវបានចាត់ចំណាត់ថ្នាក់ដូចតទៅ ០%-៧៨%៖ ស្ថានភាពធ្ងន់ធ្ងរ ៧៩%-៨៨%៖ មិនស្របតាមបទដ្ឋាន ៨៩%-១០០%៖ ស្របតាមបទដ្ឋាន។

រូបភាព ១.៧ បង្ហាញពីស្ថានភាពគួរឱ្យបារម្ភចំពោះការអនុវត្តបទដ្ឋានអប្បបរមាទាំងនៅក្នុងមណ្ឌលរដ្ឋ និងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាលចាប់ពីឆ្នាំ២០១៩ មកដល់ឆ្នាំ២០២៤។ នៅឆ្នាំ២០២៤ ក្នុងចំណោមមណ្ឌលរដ្ឋទាំង២១មណ្ឌល មានមណ្ឌលចំនួន ១៣ ឬ៦២% ដែលបានអនុវត្តស្របតាមបទដ្ឋានអប្បបរមា ចំណែកឯមណ្ឌលចំនួន៤ (១៩%) បានអនុវត្តមិនស្របតាមបទដ្ឋានអប្បបរមា និងមណ្ឌលចំនួន៤ទៀត (១៩%) មានស្ថានភាពធ្ងន់ធ្ងរ។

ដូចគ្នានេះដែរ នៅឆ្នាំ២០២៤ មណ្ឌលអង្គការមិនមែនរដ្ឋាភិបាលចំនួន៨៩ (ស្មើនឹង៦២%) បានអនុវត្តស្របតាមបទដ្ឋានអប្បបរមា ៣៤មណ្ឌល (ស្មើនឹង២៤%) មិនបានអនុវត្តស្របតាមបទដ្ឋាន និង២១មណ្ឌល (ស្មើនឹង១៤%) មានស្ថានភាពធ្ងន់ធ្ងរ។ បើប្រៀបធៀបទិន្នន័យរបស់មណ្ឌលទាំងពីរប្រភេទនេះ នៅឆ្នាំ២០២៤ ទៅនឹងឆ្នាំ២០១៩ ការអនុវត្តនេះមានភាពប្រសើរឡើងតិចតួចប៉ុណ្ណោះ ដែលជិត៤០%នៃមណ្ឌលស្ថិតក្រោមបទដ្ឋានអប្បបរមា។

រូបភាព ១.៧ ចំនួនមណ្ឌលថែទាំកុមារ បែងចែកទៅតាមបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសចំពោះកុមារ និងឆ្នាំ




ចំពោះលទ្ធផលនៃការអនុវត្តបទដ្ឋានអប្បបរមា នៅតាមការថែទាំតាមសហគមន៍ ក៏មិនសូវខុសពីមណ្ឌលដែរ។ ការថែទាំភាគច្រើនស្ថិតក្រោមបទដ្ឋានអប្បបរមា។ មានតែការថែទាំតាមផ្ទះស្នាក់នៅជាក្រុមតែប៉ុណ្ណោះ ដែលមានកម្រិតប្រសើរជាងគេ គឺផ្ទះស្នាក់នៅជាក្រុមចំនួន ៨២% (១៨កន្លែងក្នុងចំណោម២២កន្លែង) បានអនុវត្តស្របតាមបទដ្ឋាន។

រូបភាព ១.៨ ចំនួនកន្លែងថែទាំតាមសហគមន៍ បែងចែកទៅតាមបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសចំពោះកុមារ និងឆ្នាំ



## ១.៤ ការចុះបញ្ជី

ដើម្បីទទួលបានការទទួលស្គាល់ស្របច្បាប់នៅកម្ពុជាសមាគម និង អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ត្រូវអនុវត្តតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឆ្នាំ២០១៥។ ច្បាប់នេះបានកំណត់ថា សមាគម និង អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ និងសមាគម និង អង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវចុះបញ្ជីនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

យោងតាមរបកគំហើញទាំងនេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលភាគច្រើនចុះបញ្ជីជាមួយក្រសួង ដែលមានចំនួនដល់ទៅ ៧៣% (ស្មើនឹង១៨៤កន្លែង) នៅឆ្នាំ២០២៤។ នៅឆ្នាំដដែរនេះ ចំនួនកន្លែងថែទាំកុមារ ដែលមិនបានចុះបញ្ជីជាមួយក្រសួង មានចំនួន១៨% (ស្មើនឹង ៤៥កន្លែង)។ និន្នាការនេះមិនសូវមានការប្រែប្រួលទេ តាំងពីឆ្នាំ២០១៩មក។

រូបភាព ១.៩ ចំនួនកន្លែងថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជី បែងចែកទៅតាមឆ្នាំ




*សម្គាល់៖ ក្រាហ្វិកនេះមិនរាប់បញ្ចូលគ្មានទិន្នន័យ។*

រូបភាព ១.១០ ចំនួនកន្លែងថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជី បែងចែកទៅតាមប្រភេទ




*សម្គាល់៖ ក្រាហ្វិកនេះមិនរាប់បញ្ចូលគ្មានទិន្នន័យ។*

## ១.៥ ការផ្តល់លិខិតអនុញ្ញាត

រាល់មណ្ឌលថែទាំកុមារទាំងអស់របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់សេវាថែទាំកុមារ ត្រូវតែមានលិខិតអនុញ្ញាតពី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីដំណើរការដោយស្របច្បាប់[4]។ នៅឆ្នាំ២០១៩ មានតែអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣៣% (៦៩កន្លែង) ប៉ុណ្ណោះ ដែលបានទទួលលិខិតអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្របពេលដែលមណ្ឌលចំនួន ៦៦% (១៣៩កន្លែង) ពុំមានលិខិតអនុញ្ញាតឡើយ។ បើគិតជាភាគរយ នៅឆ្នាំ២០២៤ ស្ថានភាពនេះមានភាពល្អប្រសើរឡើងវិញ ដោយមណ្ឌលមានលិខិតអនុញ្ញាតកើនឡើងដល់ ទៅចំនួន ៤៥% (៦៥កន្លែង) និងមណ្ឌល ពុំមានលិខិតអនុញ្ញាតថយចុះមកចំនួន ៥៤% (៧៨កន្លែង) (រូបភាព ១.១១)។

រូបភាព ១.១១ ចំនួនមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលបានទទួលលិខិតអនុញ្ញាត ពីក្រសួង ស.អ.យ. បែងចែកទៅតាមឆ្នាំ




## ១.៦ ចំនួនអង្គការដៃគូថែទាំតាមសហគមន៍ដែលមានអនុស្សរណៈនៃការយោគយល់គ្នា (MOU)

ក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅ ចំនួនអង្គការដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) មានការកែលម្អគួរឱ្យកត់សម្គាល់ ដូចជា ភាគរយសរុបនៃកន្លែងថែទាំកុមារតាមសហគមន៍ដែលមាន MOU ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានកើនឡើងពី ១៥% ទៅ ៤០% (១៧ ទៅ ៣៥កន្លែង) ចំណែកឯភាគរយនៃកន្លែងថែទាំកុមារ ដែលពុំមាន MOU បានធ្លាក់ចុះពី ៧៦% ទៅ ៥៤% (៨៩ ទៅ ៤៧) (រូបភាព ១.១២)។ បន្ថែមលើនេះ កន្លែងថែទាំកុមារតាមសហគមន៍ ស្ទើរតែគ្រប់ប្រភេទបានបង្ហាញអំពីការកើនឡើងនូវការចុះ MOU ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅក្នុងរយៈពេលនេះ ជាពិសេស វត្តអារាម និងកន្លែងសាសនា និងផ្ទះស្នាក់នៅជាក្រុម (រូបភាព ១.១៣)។ នៅឆ្នាំ២០២៤ ប្រហែល៤០% នៃកន្លែងថែទាំកុមារតាមសហគមន៍ ដែលមិនបានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះអនុស្សារណៈជាមួយក្រសួងផ្សេងទៀត ដូចជា ក្រសួងធម្មការ និងសាសនា និងក្រសួងអប់រំ យុវជន និងកីឡា។

4 វត្តអារាមនិងកន្លែងថែទាំបែបសាសនា អន្តេវាសិកដ្ឋាន ផ្ទះជាក្រុម និង ផ្ទះស្នាក់នៅបណ្តោះអាសន្ន មិនតម្រូវអោយមានលិខិតអនុញ្ញាតិពីក្រសួង ស.អ.យ ទេ។

រូបភាព ១.១២ ចំនួនកន្លែងថែទាំកុមារតាមសហគមន៍ ដែលមាន MOU ជាមួយក្រសួង ស.អ.យ. បែងចែកទៅតាមឆ្នាំ




រូបភាព ១.១៣ ចំនួនកន្លែងថែទាំកុមារតាមសហគមន៍ ដែលមាន MOU ជាមួយក្រសួង ស.អ.យ. បែងចែកទៅតាមប្រភេទ




## ១.៧ ផែនការអនាគត

យោងតាមរបកគំហើញពីអធិការកិច្ចនៅឆ្នាំ២០២៤ ពាក់កណ្ដាលនៃកន្លែងថែទាំកុមារ នឹងបន្តផ្ដល់សេវាសមាហរណកម្ម ដើម្បីជួយឱ្យកុមារវិលត្រលប់ទៅកាន់គ្រួសាររបស់ពួកគេវិញ។ បន្ថែមលើនេះកន្លែងថែទាំកុមារ ចំនួន១ នឹងត្រូវបិទ ហើយកន្លែងថែទាំកុមារចំនួនពីរ នឹងធ្វើការបង្វែរទៅជាការថែទាំប្រភេទផ្សេងទៀត (រូបភាព ១.១៤)។

### រូបភាព ១.១៤ ចំនួនកន្លែងថែទាំកុមារ ដែលមានផែនការអនាគត



# ផ្នែកទី២៖ ស្ថានភាពកុមារដែលកំពុងរស់នៅក្នុងកន្លែងថែទាំកុមារ

## របកគំហើញសំខាន់ៗ

- **កុមារនៅក្នុងកន្លែងថែទាំកុមារ៖** ភាគរយនៃកុមាររស់នៅក្នុងកន្លែងថែទាំកុមារបានធ្លាក់ចុះចំនួន ៧៣% (១៩.១១០នាក់) គឺពីចំនួន ២៦.១៨៧នាក់ ឆ្នាំ២០១៥ មកត្រឹមចំនួន ៧.០៧៧នាក់ នៅឆ្នាំ២០២៤។ ភាគរយនៃកុមាររស់នៅក្នុងមណ្ឌលថែទាំកុមារបានធ្លាក់ចុះចំនួន៧០% ពីចំនួន ១៦.៥៧៩នាក់ នៅឆ្នាំ២០១៥ មកចំនួន ៥.០៥៥នាក់ នៅឆ្នាំ២០២៤។ នៅឆ្នាំ២០២៤ មណ្ឌលរដ្ឋមានកុមារចំនួន ៧៩៦នាក់ មណ្ឌលអង្គការមិនមែនរដ្ឋាភិបាលចំនួន ៤.២៥៩នាក់ វត្តអារាម និងកន្លែងសាសនាចំនួន ៤៤០នាក់ អន្តេវាសិកដ្ឋានចំនួន ១.១៧៨នាក់ ផ្ទះស្នាក់នៅជាក្រុមចំនួន ២៧០នាក់ និងស្នាក់នៅបណ្ដោះអាសន្ន និងកន្លែងស្នាក់នៅបន្ទាន់ចំនួន ១៣៤នាក់ ។
- **កុមារមានពិការភាព៖** នៅឆ្នាំ២០២៤ កុមារមានពិការភាពដែលរស់នៅក្នុងកន្លែងថែទាំកុមារ មានចំនួន ៥៥៩នាក់ ក្នុងនោះកុមារាចំនួន ២៩៧នាក់ (៥៣%) និងកុមារីចំនួន ២៦២នាក់ (៤៧%)។ ក្នុងចំណោមកុមារទាំងនេះ កុមារមានពិការភាពភាគច្រើនរស់នៅក្នុងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាល ដែលមានចំនួន ១៨៦នាក់ មណ្ឌលរដ្ឋ ១៨១នាក់ អន្តេវាសិកដ្ឋាន ១៦៥នាក់។ ពីឆ្នាំ២០១៩ មកដល់ឆ្នាំ២០២៤ ចំនួនកុមារមានពិការភាពនៅក្នុងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាល បានថយចុះគួរឱ្យកត់សម្គាល់ពីចំនួន ៤៥០នាក់ មកត្រឹម១៨៦នាក់ ស្របពេលដែលចំនួនកុមារមានពិការភាពនៅក្នុងមណ្ឌលរដ្ឋ បានកើនឡើងពី ១៧០នាក់ ទៅ១៨១នាក់ ស្មើនឹង៦% ដែលបញ្ជាក់ថាកុមារទាំងនេះរស់នៅក្នុងមណ្ឌលរដ្ឋ មានរយៈពេលជាច្រើនឆ្នាំ។
- **ស្ថានភាពឪពុកម្ដាយ៖** នៅឆ្នាំ២០២៤ កុមារចំនួន ៧៧% (៥.៤៧១នាក់) នៅក្នុងកន្លែងថែទាំកុមារយ៉ាងហោចណាស់ មានឪពុក ឬម្ដាយម្នាក់នៅរស់ ចំណែកកុមារចំនួន ៣៣% (១.៦០៦នាក់) កំព្រាទាំងម្ដាយនិងឪពុក។
- **បទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសចំពោះកុមារ៖** នៅឆ្នាំ២០២៤ មណ្ឌលរដ្ឋមានកុមារចំនួន៧២% (៥៧៥នាក់) រស់នៅស្របតាមបទដ្ឋានអប្បបរមា កុមារចំនួន២០% (១៥៦នាក់) រស់មិនស្របតាមបទដ្ឋានអប្បបរមា និងកុមារចំនួន៨% ស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ (៦៥នាក់)។ មណ្ឌលអង្គការមិនមែនរដ្ឋាភិបាល កុមារមានកុមារចំនួន៦៥% (២.៧៨១នាក់) រស់នៅស្របតាមបទដ្ឋានអប្បបរមា និងកុមារចំនួន២៧% (១.១៣៨នាក់) រស់មិនស្របតាមបទដ្ឋានអប្បបរមា និងកុមារចំនួន៨% (៣៤០នាក់) ស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ។ កន្លែងថែទាំតាមសហគមន៍ដែលបានអនុវត្តស្របតាមបទដ្ឋាន និងមានភាគរយនៃកុមាររស់នៅច្រើនជាងគេ គឺផ្ទះស្នាក់នៅជាក្រុម (៧៩% ឬ២១២នាក់) ចំណែកឯកន្លែងថែទាំតាមសហគមន៍ដែលមិនបានអនុវត្តស្របតាមបទដ្ឋាន និងមានភាគរយនៃកុមាររស់នៅច្រើនជាងគេ គឺកន្លែងសាសនា (៥០% ឬ៣៩៨នាក់) និងអន្តេវាសិកដ្ឋាន (៤៩% ឬ៥៧៨នាក់)។ ស្ថានភាពកុមារមានពិការភាព ដែលរស់នៅក្នុងមណ្ឌលរដ្ឋ (១៦៦នាក់ ឬ៩២%) អន្តេវាសិកដ្ឋាន (១៦៣នាក់ ឬ៩៩%) និងផ្ទះស្នាក់នៅជាក្រុម (២២នាក់ ឬ៨៨%) មានលក្ខណៈប្រសើរជាងកន្លែងថែទាំផ្សេងៗទៀត។

## ២.១ ចំនួនកុមាររស់នៅក្នុងកន្លែងថែទាំកុមារ

រូបភាព ២.១ ចំនួនកុមាររស់នៅក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមឆ្នាំ




ចាប់ពីឆ្នាំ២០១៥ មកដល់ឆ្នាំ២០២៤ ចំនួនកុមារកំពុងរស់នៅក្នុងកន្លែងថែទាំកុមារ បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ (រូបភាព ២.១)។ នៅឆ្នាំ២០១៥ កុមារចំនួន ២៦.១៨៧នាក់បានរស់នៅក្នុងកន្លែងថែទាំកុមារ។ ចំនួននេះបានធ្លាក់ចុះយ៉ាងរហ័សនៅក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក ដោយនៅត្រឹមឆ្នាំ២០២៤ កុមារចំនួនតែ ៧.០៧៧នាក់ប៉ុណ្ណោះដែលរស់នៅក្នុងកន្លែងថែទាំកុមារ។ ជារួម ចំនួនកុមារនៅក្នុងកន្លែងថែទាំកុមារ បានធ្លាក់ចុះចំនួន ៧៣% (១៩.១១០នាក់) ដោយចំនួនកុមារាធ្លាក់ចុះចំនួន ៧៦% (១០.៣៣៥នាក់) ហើយចំនួនកុមារីបានធ្លាក់ចុះចំនួន ៧០% (៨.៧៧៥នាក់)។

នៅក្នុងចំណោមកន្លែងថែទាំកុមារគ្រប់ប្រភេទទាំងអស់ មណ្ឌលថែទាំមានកុមាររស់នៅច្រើនជាងគេ (តារាង ១)។ នៅឆ្នាំ២០២៤ កុមារចំនួន ៥.០៥៥នាក់ (៧១%) រស់នៅក្នុងមណ្ឌលថែទាំ កុមារចំនួន ១.១៧៨នាក់ (១៧%) រស់នៅក្នុងអន្តេវាសិកដ្ឋាន កុមារចំនួន ៤៤០នាក់ (៦%) រស់នៅក្នុងវត្តអារាម និងកន្លែងសាសនាដទៃទៀតដែលផ្តល់ការថែទាំ កុមារចំនួន ២៧០នាក់ (៤%) រស់នៅក្នុងផ្ទះស្នាក់នៅជាក្រុម និងកុមារចំនួន ១៣៤នាក់ (២%) រស់នៅក្នុងផ្ទះស្នាក់នៅបណ្តោះអាសន្ន។

ពីឆ្នាំ២០១៥ មកដល់ឆ្នាំ២០២៤ ចំនួនកុមារនៅក្នុងកន្លែងថែទាំកុមារបានធ្លាក់ចុះ។ កុមារនៅក្នុងមណ្ឌលបានធ្លាក់ចុះចំនួន ១១.៥២៤នាក់ (៧០%) កុមារនៅក្នុងអន្តេវាសិកដ្ឋានបានធ្លាក់ចុះចំនួន ៤.៨៦១នាក់ (៨០%) កុមារនៅក្នុងវត្តអារាម និងកន្លែងសាសនាដទៃទៀតដែលផ្តល់ការថែទាំបានធ្លាក់ចុះចំនួន ៩០៩នាក់ (៦៧%) កុមារនៅក្នុងផ្ទះស្នាក់នៅជាក្រុមបានធ្លាក់ចុះចំនួន ១.៣២២នាក់ (៨៣%) និងកុមារនៅក្នុងផ្ទះស្នាក់នៅបណ្តោះអាសន្ន/កន្លែងស្នាក់នៅបន្ទាន់បណ្តោះអាសន្នបានធ្លាក់ចុះ ៤៩៤នាក់ (៧៩%)។

ពាក់ព័ន្ធនឹងក្រុមអាយុ ជាងពាក់កណ្តាលនៃកុមារនៅក្នុងកន្លែងថែទាំកុមារ មានអាយុ ៦-១៤ឆ្នាំ (៥៨%) បន្ទាប់មកគឺកុមារអាយុ ១៥-១៧ឆ្នាំ (៣៤%) កុមារអាយុ ៤-៥ឆ្នាំ (៥%) និងកុមារអាយុ ០-៣ឆ្នាំ (៣%) (តារាង ២)។

តារាង ១ ចំនួនកុមាររស់នៅក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមប្រភេទ និងឆ្នាំ

| ឆ្នាំ | ២០១៥ | | | ២០១៩ | | | ២០២២ | | | ២០២៣ | | | ២០២៤ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រភេទ | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ១.មណ្ឌលថែទាំកុមារសរុប | ៨៨០៣ | ៧៧៧៦ | ១៦៥៧៩ | ៣៤៦១ | ៣៣១៧ | ៦៧៧៨ | ២៦២៤ | ២៤៥១ | ៥០៧៥ | ២៦៥៨ | ២៥២៣ | ៥១៨១ | ២៤៨០ | ២៥៧៥ | ៥០៥៥ |
| • មណ្ឌលរដ្ឋ | ៦៥៥ | ៥០៧ | ១១៦២ | ៤១១ | ២៨៥ | ៦៩៦ | ៤០៣ | ៣០៦ | ៧០៩ | ៤០៤ | ២៩០ | ៦៩៤ | ៤៦៥ | ៣៣១ | ៧៩៦ |
| • មណ្ឌលអង្គការមិនមែនរដ្ឋាភិបាល | ៨៨០៣ | ៧៧៧៦ | ១៦៥៧៩ | ៣០៥០ | ៣០៣២ | ៦០៨២ | ២២២១ | ២១៤៥ | ៤៣៦៦ | ២២៥៤ | ២២៣៣ | ៣៤៨៧ | ២០១៥ | ២២៤៤ | ៤២៥៩ |
| ២.វត្តអារាម និងកន្លែងសាសនា | ៦៧៦ | ៦៧៣ | ១៣៤៩ | ៤៣១ | ៣១៤ | ៧៤៥ | ៣៥៩ | ២៧៤ | ៦៣៣ | ១៨៤ | ១៥៦ | ៣៤០ | ២២៩ | ២១១ | ៤៤០ |
| ៣.អន្តេវាសិកដ្ឋាន | ៣១៣០ | ២៩០៩ | ៦០៣៩ | ៨៣៣ | ៦៦១ | ១៤៩៤ | ៤៦៩ | ៧២៩ | ១១៩៨ | ៥៦៨ | ៦៣២ | ១២០០ | ៤៣៨ | ៧៤០ | ១១៧៨ |
| ៤.ផ្ទះស្នាក់នៅជាក្រុម | ៧៧២ | ៨២០ | ១៥៩២ | ៤៥ | ៦១ | ១០៦ | ១០៦ | ១៣៦ | ២៤២ | ១២៦ | ១៦៧ | ២៩៣ | ១១៨ | ១៥២ | ២៧០ |
| ៥.ផ្ទះស្នាក់នៅបណ្តោះអាសន្ន | ២៨០ | ៣៤៨ | ៦២៨ | ១៤៩ | ១៩៦ | ៣៤៥ | ៣១៣ | ៣៥២ | ៦៦៥ | ៣៥ | ៣០ | ៦៥ | ៦១ | ៧៣ | ១៣៤ |
| **សរុប** | **១៣៦៦១** | **១២៥២៦** | **២៦១៨៧** | **៤៩១៩** | **៤៥៤៩** | **៩៤៦៨** | **៣៨៧១** | **៣៩៤២** | **៧៨១៣** | **៣៥៧១** | **៣៥០៨** | **៧០៧៩** | **៣៣២៦** | **៣៧៥១** | **៧០៧៧** |

តារាង ២ ចំនួនកុមាររស់នៅក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមក្រុមអាយុ ឆ្នាំ២០២៤

| ឆ្នាំ | ០-៣ឆ្នាំ | | | ៤-៥ឆ្នាំ | | | ៦-១៤ឆ្នាំ | | | ១៥-១៧ឆ្នាំ | | | កុមារសរុប | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រភេទ | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ១.មណ្ឌលថែទាំកុមារ | ១០៣ | ៩៣ | ១៩៦ | ១៤៩ | ១៥២ | ៣០១ | ១៥៩៩ | ១៥២៥ | ៣១២៤ | ៦២៩ | ៨០៥ | ១៤៣៤ | ២៤៨០ | ២៥៧៥ | ៥០៥៥ |
| • មណ្ឌលរដ្ឋ | ១៨ | ១២ | ៣០ | ៤១ | ២៥ | ៦៦ | ២៧៧ | ១៩៥ | ៤៧២ | ១២៩ | ៩៩ | ២២៨ | ៤៦៥ | ៣៣១ | ៧៩៦ |
| • មណ្ឌលអង្គការមិនមែនរដ្ឋាភិបាល | ៨៥ | ៨១ | ១៦៦ | ១០៨ | ១២៧ | ២៣៥ | ១៣២២ | ១៣៣០ | ២៦៥២ | ៥០០ | ៧០៦ | ១២០៦ | ២០១៥ | ២២៤៤ | ៤២៥៩ |
| ២.វត្តអារាម និងកន្លែងសាសនា | ៣ | ០ | ៣ | ៨ | ៩ | ១៧ | ១២៩ | ១២៦ | ២៥៥ | ៨៩ | ៧៦ | ១៦៥ | ២២៩ | ២១១ | ៤៤០ |
| ៣.អន្តេវាសិកដ្ឋាន | ១០ | ៥ | ១៥ | ១០ | ៨ | ១៨ | ១៧០ | ២៧១ | ៤៤១ | ២៤៨ | ៤៥៦ | ៧០៤ | ៤៣៨ | ៧៤០ | ១១៧៨ |
| ៤.ផ្ទះស្នាក់នៅជាក្រុម | ២ | ២ | ៤ | ៣ | ៣ | ៦ | ៨៣ | ១០០ | ១៨៣ | ៣០ | ៤៧ | ៧៧ | ១១៨ | ១៥២ | ២៧០ |
| ៥.ផ្ទះស្នាក់នៅបណ្តោះអាសន្ន | ៨ | ៥ | ១៣ | ៩ | ៨ | ១៧ | ៣០ | ៤២ | ៧២ | ១៤ | ១៨ | ៣២ | ៦១ | ៧៣ | ១៣៤ |
| **សរុប** | **១២៦** | **១០៥** | **២៣១** | **១៧៩** | **១៨០** | **៣៥៩** | **២០១១** | **២០៦៤** | **៤០៧៥** | **១០១០** | **១៤០២** | **២៤១២** | **៣៣២៦** | **៣៧៥១** | **៧០៧៧** |

## ២.២ ចំនួនយុវជន (អាយុពី១៨ឆ្នាំឡើង) រស់នៅក្នុងកន្លែងថែទាំកុមារ

នៅឆ្នាំ២០១៥ យុវជនចំនួន ៩.១៨៧នាក់ រស់នៅក្នុងកន្លែងថែទាំកុមារ។ រយៈពេលដប់ឆ្នាំក្រោយមក ចំនួននេះបានធ្លាក់ចុះចំនួន ៨៣% ដែលធ្វើឱ្យយុវជនមានចំនួនត្រឹម ១.៦០៥នាក់ប៉ុណ្ណោះ។

តារាង ៣ ចំនួនយុវជនរស់នៅក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមឆ្នាំ

| ឆ្នាំ | ២០១៥ | | | ២០១៩ | | | ២០២២ | | | ២០២៣ | | | ២០២៤ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រភេទ | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ១.មណ្ឌលថែទាំកុមារ | ៤៧១៣ | ២០៥៦ | ៦៧៦៩ | ៨៦៣ | ៩២៩ | ១៧៩២ | ៦០៩ | ៦២៩ | ១២៣៨ | ៦៤៣ | ៧៤៦ | ១៣៨៩ | ៥៣៧ | ៥៩៩ | ១១៣៦ |
| • មណ្ឌលរដ្ឋ | គ្មានទិន្នន័យ | គ្មានទិន្នន័យ | គ្មានទិន្នន័យ | ១៦៧ | ១៧៦ | ៣៤៣ | ១៦០ | ១២៦ | ២៨៦ | ១៦៦ | ១៤៥ | ៣១១ | ១៣៦ | ១២៤ | ២៦០ |
| • មណ្ឌលអង្គការមិនមែនរដ្ឋាភិបាល | ៤៧១៣ | ២០៥៦ | ៦៧៦៩ | ៦៩៦ | ៧៥៣ | ១៤៤៩ | ៤៤៩ | ៥០៣ | ៩៥២ | ៤៧៧ | ៦០១ | ១០៧៨ | ៤០១ | ៤៧៥ | ៨៧៦ |
| ២.វត្តអារាម និងកន្លែងសាសនា | ១៧៩ | ៤៣ | ២២២ | ៨៣ | ៤១ | ១២៤ | ៤៥ | ៤៤ | ៨៩ | ៤៤ | ៣០ | ៧៤ | ៣៣ | ២៩ | ៦២ |
| ៣.អន្តេវាសិកដ្ឋាន | ៦១២ | ៧១៩ | ១៣៣១ | ៣៤៩ | ២២៣ | ៥៧២ | ២០៣ | ២៦៨ | ៤៧១ | ១៥៣ | ២២១ | ៣៧៤ | ១៤៩ | ១៦៥ | ៣១៤ |
| ៤.ផ្ទះស្នាក់នៅជាក្រុម | ២២៤ | ៣២០ | ៥៤៤ | ៧ | ៩ | ១៦ | ៣៦ | ៩១ | ១២៧ | ៤១ | ៨០ | ១២១ | ៣១ | ៥០ | ៨១ |
| ៥.ផ្ទះស្នាក់នៅបណ្តោះអាសន្ន | ១៣៦ | ១៨៥ | ៣២១ | ១០ | ១១ | ២១ | ៣៣ | ៤៣ | ៧៦ | ០ | ១៦ | ១៦ | ១ | ១១ | ១២ |
| សរុប | ៥៨៦៤ | ៣៣២៣ | ៩១៨៧ | ១៣១២ | ១២១៣ | ២៥២៥ | ៩២៦ | ១០៧៥ | ២០០១ | ៨៨១ | ១០៩៣ | ១៩៧៤ | ៧៥១ | ៨៥៤ | ១៦០៥ |

# ២.៣ កុមារមានពិការភាព

នៅឆ្នាំ២០២៤ កន្លែងថែទាំកុមារ មានកុមារមានពិការភាពប្រភេទផ្សេងៗគ្នាចំនួន ៥៥៩នាក់ (៨%) ក្នុងនោះ កុមារាមានចំនួន ២៩៧នាក់ (៥៣%) និងកុមារីមានចំនួន ២៦២នាក់ (៤៧%) (រូបភាព ២.២)។ កុមារមានពិការភាពកាយសម្បទា មានចំនួនច្រើនជាងគេ (៣៧០នាក់ ឬ ៤៧%) បន្ទាប់មក គឺកុមារមានពិការភាពសតិបញ្ញា (២៧១នាក់ ឬ ៣៤%) និងកុមារមានពិការភាពញាណដឹង (១៥៤នាក់ ឬ ១៩%) (រូបភាព ២.៣)។ កុមារមានពិការភាពដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារអង្គការមិនមែនរដ្ឋាភិបាលមានចំនួនច្រើនជាងគេ គឺ១៨៦នាក់ បន្ទាប់មកមណ្ឌលថែទាំកុមាររដ្ឋ ចំនួន ១៨១នាក់ អន្តេវាសិកដ្ឋាន ចំនួន ១៦៥នាក់ (រូបភាព ២.៤)។

ពីឆ្នាំ២០១៩ មកដល់ឆ្នាំ២០២៤ ចំនួនកុមារមានពិការភាពសរុបក្នុងកន្លែងថែទាំកុមារបានធ្លាក់ចុះចំនួន ១៥៩នាក់ក្តី ដែលភាគច្រើនបណ្តាលមកពីការថយចុះចំនួនកុមារមានពិការភាព រស់ក្នុងមណ្ឌលថែទាំកុមារអង្គការមិនមែនរដ្ឋាភិបាល ពីចំនួន ៤៥០នាក់ មកចំនួន ១៨៦នាក់។ ផ្ទុយពីនេះ ចំនួនកុមារមានពិការភាពរស់នៅក្នុងមណ្ឌលថែទាំកុមាររដ្ឋ បានកើនឡើងពីចំនួន ១៧០នាក់ ទៅចំនួន ១៨១នាក់ ដែលនេះបញ្ជាក់ថាកុមារទាំងនោះរស់នៅក្នុងមណ្ឌលរដ្ឋមានរយៈពេលច្រើនឆ្នាំ (រូបភាព ២.៤)។

រូបភាព ២.២ ចំនួនកុមារមានពិការភាពរស់នៅក្នុងកន្លែងថែទាំកុមារ ឆ្នាំ២០២៤



រូបភាព ២.៣ ចំនួនកុមារមានពិការភាពរស់នៅក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមប្រភេទពិការភាព និងឆ្នាំ




រូបភាព ២.៤ ចំនួនកុមារមានពិការភាពរស់នៅក្នុងកន្លែងថែទាំ បែងចែកទៅតាមប្រភេទកន្លែងថែទាំ និងឆ្នាំ




## ២.៤ ស្ថានភាពឪពុកម្តាយរបស់កុមាររស់នៅក្នុងកន្លែងថែទាំ

នៅឆ្នាំ២០២៤ កុមារនៅក្នុងកន្លែងថែទាំកុមារ ចំនួន ៧៧% (៥.៨៧១នាក់) យ៉ាងហោចណាស់ មានឪពុក ឬម្តាយម្នាក់នៅរស់។ ក្នុងចំណោមកុមារទាំងនេះ ៣៩% (២.៧៧២នាក់) មានឪពុកម្តាយទាំងពីរនាក់នៅរស់ ចំណែកឯកុមារចំនួន ៣៨% (២.៦៩៩នាក់) មានម្តាយ ឬឪពុកនៅរស់។ ផ្ទុយទៅវិញ កុមារនៅក្នុងកន្លែងថែទាំកុមារ ចំនួន ២៣% (១.៦០៦នាក់) កំព្រាទាំងម្តាយនិងឪពុក។

រូបភាព ២.៥ ចំនួនកុមារនៅក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមស្ថានភាពនៅរស់របស់ឪពុកម្ដាយ ឆ្នាំ២០២៤




## ២.៥ កម្រិតនៃការអប់រំ

កុមារនៅក្នុងកន្លែងថែទាំកុមារ ភាគច្រើនរៀនពីថ្នាក់ទី១ ដល់ថ្នាក់ទី៩ ដែលមានចំនួន ៥.១១៣នាក់។ បន្ទាប់មកគឺកុមារដែលរៀនថ្នាក់១០ ដល់ថ្នាក់ទី១២ ដែលមានចំនួន ១.៧២៥នាក់ និងកុមាររៀនវគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ ដែលមានចំនួន ៩៦៩នាក់។ បន្ថែមលើនេះ កុមារប្រមាណ ៥៣៩នាក់ កំពុងរៀននៅថ្នាក់មត្តេយ្យសិក្សា ចំណែកឯកុមារចំនួន ២៤៣នាក់ ក្នុងក្រុមអាយុដូចគ្នានេះមិនបានចុះឈ្មោះចូលរៀនឡើយ។

រូបភាព ២.៦ ចំនួនកុមារនៅក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមកម្រិតនៃការអប់រំ ឆ្នាំ២០២៤




*សម្គាល់៖ អ្នកឆ្លើយសំណួរអាចជ្រើសរើសជម្រើសច្រើនជាងមួយ។*

## ២.៦ ការបញ្ជូនកុមារមកថែទាំក្នុងកន្លែងថែទាំកុមារ

នៅឆ្នាំ២០២៤ ទិន្នន័យបានបង្ហាញថា កុមារចំនួន ៤៦% (៣.២៣៧នាក់) ត្រូវបានបញ្ជូនចូលក្នុងកន្លែងថែទាំកុមារ ដោយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ (គ.ក.ន.ក) មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអាជ្ញាធរមូលដ្ឋាន។ បន្ថែមលើនេះ កុមារចំនួន ៣៩% (២.៧២៧នាក់) ត្រូវបានបញ្ជូនមកដោយ ឪពុកម្តាយ ឬសាច់ញាតិរបស់ពួកគេ ហើយកុមារចំនួន ១១% (៧៧៧នាក់) ត្រូវបាននាំមកដោយបុគ្គលិកកន្លែងថែទាំ (រូបភាព ២.៧)។

នៅពេលពិនិត្យមើលថា តើការទុកដាក់កុមារទាំងនេះនៅក្នុងកន្លែងថែទាំកុមារ បានអនុវត្តតាមរយៈនីតិវិធីទុកដាក់កុមារត្រឹមត្រូវរបស់ក្រសួង ស.អ.យ. ដែរឬទេ រូបភាព ២.៨ បង្ហាញថា កុមារដែលត្រូវបានទុកដាក់ ដោយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ (គ.ក.ន.ក) មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអាជ្ញាធរមូលដ្ឋាន គឺភាគច្រើនបានអនុលោមទៅតាមនីតិវិធី នៃការទុកដាក់កុមារក្នុងកម្រិតខ្ពស់បំផុត។ ឧទាហរណ៍ កុមារចំនួន ៩៥% (៣.០៦៨នាក់) ត្រូវបានទុកដាក់ដោយអាជ្ញាធរមូលដ្ឋាន កុមារចំនួន ៦១% (១.៦៧១នាក់) ត្រូវបានទុកដាក់ដោយឪពុកម្តាយ/សាច់ញាតិ និងកុមារចំនួន ៦៩% (៥៤០នាក់) ត្រូវបានទុកដាក់ដោយបុគ្គលិកកន្លែងថែទាំ បានអនុវត្តទៅតាមនីតិវិធីត្រឹមត្រូវ។

រូបភាព ២.៧ ចំនួនកុមារដែលត្រូវបានបញ្ជូនចូលក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមប្រភព ឆ្នាំ២០២៤




*សម្គាល់៖ ការមកដោយខ្លួនឯង មានន័យថា កុមារបានចូលទៅក្នុងកន្លែងថែទាំ ដោយខ្លួនឯង។ ចំពោះប្រភេទផ្សេងទៀត ពុំមានព័ត៌មានលម្អិតពីទិន្នន័យអធិការកិច្ចឡើយ។*

រូបភាព ២.៨ ចំនួនកុមារដែលត្រូវបានបញ្ជូនចូលក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមនីតិវិធីទុកដាក់កុមាររបស់ក្រសួង ស.អ.យ. ឆ្នាំ២០២៤




## ២.៧ កុមាររស់នៅក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសចំពោះកុមារ

នៅឆ្នាំ២០២៤ កុមារប្រមាណ ៤.២១៤នាក់ (៥៩%) កំពុងរស់នៅក្នុងកន្លែងថែទាំកុមារ ដែលបានអនុវត្តស្របតាមបទដ្ឋានអប្បបរមា។ ចំណែកឯកុមារចំនួន ១.៨៩១នាក់ (២៧%) កំពុងរស់នៅក្នុងកន្លែងថែទាំកុមារ ដែលមិនបានអនុវត្តស្របតាមបទដ្ឋាន និងកុមារចំនួន ៩៧២នាក់ (១៤%) ស្ថិតនៅក្នុងកន្លែងថែទាំកុមារដែលមានស្ថានភាពធ្ងន់ធ្ងរ ដែលមានចំនួនច្រើនគួរឱ្យកត់សម្គាល់។

រូបភាព ២.៩ ចំនួនកុមាររស់នៅក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមបទដ្ឋានអប្បបរមា ឆ្នាំ២០២៤



រូបភាព ២.១០ បង្ហាញចំនួនកុមារនៅក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២៤។ ក្រាហ្វិកនេះបង្ហាញភាពល្អប្រសើរឡើងមួយចំនួន។ ឧទាហរណ៍ កុមាររស់នៅក្នុងកន្លែងថែទាំកុមារ ដែលបានអនុវត្តស្របតាមបទដ្ឋាន បានកើនឡើងចំនួន ១០៩នាក់ (១៦%) បន្ថែមទៀត ចំណែកឯកុមារដែលរស់នៅកន្លែងថែទាំកុមារដែលមិនអនុវត្តស្របតាមបទដ្ឋានអប្បបរមា មានចំនួនតិចជាងមុនចំនួន ៥៤៦នាក់ (១៧%) និងស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរចំនួន ១៩៥៤នាក់ (១៧%)។

ចំពោះការថែទាំតាមមណ្ឌល នៅឆ្នាំ២០២៤ មណ្ឌលរដ្ឋមានកុមារចំនួន ៧២% (៥៧៥នាក់) រស់នៅស្របតាមបទដ្ឋានអប្បបរមា និងកុមារចំនួន ២៨% (២២១នាក់) រស់ក្រោមបទដ្ឋានអប្បបរមា។ នៅក្នុងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាល កុមារចំនួន ៦៥% (២.៧៨១នាក់) រស់នៅស្របតាមបទដ្ឋានអប្បបរមា និងកុមារចំនួន ៣៥% (១.៤៧៨នាក់) រស់ក្រោមបទដ្ឋានអប្បបរមា។ លទ្ធផលនេះបញ្ជាក់ថា ស្ថានភាពកុមារ ដែលរស់នៅក្នុងមណ្ឌលរដ្ឋ ប្រសើរជាងកុមារដែលរស់ក្នុងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាល ដោយភាគរយនៃកុមាររស់នៅក្នុងមណ្ឌលរដ្ឋ មានចំនួនច្រើនជាងភាគរយកុមារដែលរស់នៅក្នុងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ មណ្ឌលរដ្ឋ ក៏ដូចជាមណ្ឌលអង្គការមិនមែនរដ្ឋាភិបាល នៅមានកុមារជាច្រើនដែលបន្តរស់នៅក្រោមបទដ្ឋានអប្បបរមានៅឡើយ (១.៤៧៨នាក់) (រូបភាព ២.១១)។

ចំពោះកន្លែងថែទាំតាមសហគមន៍ បង្ហាញថា ភាគរយនៃកុមារដែលស្ថិតនៅក្នុងអន្តេវាសិកដ្ឋាន និងផ្ទះស្នាក់នៅជាក្រុម ដែលអនុវត្តស្របតាមបទដ្ឋានអប្បបរមា មានចំនួនច្រើនជាងកន្លែងថែទាំតាមសហគមន៍ផ្សេងៗទៀត ដែលមាន ៥១% (៦០០នាក់) និង៧៩% (២១២នាក់) (រូបភាព ២.១២)។ ទន្ទឹមនឹងនេះ ភាគរយនៃកុមារនៅក្នុងកន្លែងថែទាំតាមសហគមន៍ ដែលអនុវត្តមិនស្របតាមបទដ្ឋានអប្បបរមា មាននៅក្នុងអន្តេវាសិកដ្ឋាន ៤៩% (៥៧៨នាក់) និងកន្លែងសាសនា ៥០% (៣៩៨នាក់)។

រូបភាព ២.១០ ចំនួនកុមាររស់នៅក្នុងកន្លែងថែទាំកុមារ បែងចែកទៅតាមបទដ្ឋានអប្បបរមា និងឆ្នាំ



រូបភាព ២.១១ ចំនួនកុមាររស់នៅក្នុងមណ្ឌលថែទាំកុមារ បែងចែកទៅតាមបទដ្ឋានអប្បបរមា និងឆ្នាំ




រូបភាព ២.១២ ចំនួនកុមាររស់នៅក្នុងកន្លែងថែទាំតាមសហគមន៍ បែងចែកទៅតាមបទដ្ឋានអប្បបរមា និងឆ្នាំ




រូបភាព ២.១៣ និង ២.១៤ បង្ហាញថាស្ថានភាពកុមារមានពិការភាព ដែលរស់នៅក្នុងមណ្ឌលរដ្ឋ (១៦៦នាក់ ឬ៩២%) អន្តេវាសិកដ្ឋាន (១៦៣នាក់ ឬ៩៩%) និងផ្ទះស្នាក់នៅជាក្រុម (២២នាក់ ឬ៨៨%) មានលក្ខណៈប្រសើរជាងកន្លែងថែទាំផ្សេងៗទៀត។ ចំពោះកុមារមានពិការភាព រស់ក្នុងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាល ពួកគាត់មានស្ថានភាពគួរឱ្យព្រួយបារម្ភ ដែលចាប់ពីឆ្នាំ២០១៩ មកដល់ឆ្នាំ២០២៤ ភាគរយនៃកុមារមានពិការភាពនៅមណ្ឌលអង្គការមិនមែនរដ្ឋាភិបាល ដែលមិនបានអនុវត្តស្របតាមបទដ្ឋានអប្បបរមា មានចំនួនច្រើនគួរឱ្យកត់សម្គាល់ ដែលនៅឆ្នាំ២០១៩ មានចំនួន ២៧% (១២២នាក់) និងនៅឆ្នាំ២០២៤ ចំនួន ៦៨% (១២៧នាក់)។

រូបភាព ២.១៣ ចំនួនកុមារមានពិការភាព ដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ បែងចែកទៅតាមបទដ្ឋានអប្បបរមា និងឆ្នាំ




រូបភាព ២.១៤ ចំនួនកុមារមានពិការភាព ដែលរស់នៅក្នុងកន្លែងថែទាំតាមសហគមន៍ បែងចែកទៅតាមបទដ្ឋានអប្បបរមា និងឆ្នាំ



# ផ្នែកទី៣៖ អនុសាសន៍

## អនុសាសន៍

### ១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- ពង្រឹងការទប់ស្កាត់ការយកកុមារចូលមណ្ឌល ដោយមិនចាំបាច់ ជាពិសេសការបញ្ជូនកុមារមានពិការភាពមកមណ្ឌល តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយថែទាំជំនួសចំពោះកុមារ ដែលត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០២៤
- ពង្រឹងការអនុវត្តយុទ្ធសាស្ត្ររក្សាកុមារក្នុងគ្រួសារ និងយុទ្ធសាស្ត្រ ប្រាស្រ័យទាក់ទងដើម្បីបញ្ចប់អំពើហិង្សាលើកុមារ និងការទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់
- ពង្រីកការអនុវត្តយុទ្ធនាការគ្រួសាររឹងមាំ (Cambodia PROTECT) និងកម្មវិធីការចិញ្ចឹមកូនបែបវិជ្ជមានសម្រាប់ឪពុកម្តាយ និងអ្នកថែទាំ
- បង្កើនកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងធម្មការ និងសាសនា ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធនីមួយៗក្នុងការអនុវត្តអនុក្រឹត្យលេខ ១១៩ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ អនុក្រឹត្យលេខ ៣៤ ស្តីពីការផ្ទេរមុខងារទៅឱ្យរដ្ឋបាល ថ្នាក់ក្រោមជាតិ និងការអនុវត្តបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារនៅក្នុងកន្លែងថែទាំកុមារ ដោយសារទីកន្លែងសាសនា និងអន្តរាសិដ្ឋានដែលផ្តល់សេវាថែទាំមួយចំនួន មិនបានមានចុះអនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បង្កើនកិច្ចសហការជាមួយក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានី ខេត្ត និងការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ ដើម្បីប៉ាន់ប្រមាណជាបន្ទាន់នូវស្ថានភាពរបស់មណ្ឌលថែទាំកុមារ (RCIs) ដែលពុំមានលិខិតអនុញ្ញាតទទួលស្គាល់ជាមណ្ឌលថែទាំកុមារ ព្រមទាំងរាល់កន្លែងថែទាំកុមារ ដែលស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ
- ជំរុញមន្ទីរ ស.អ.យ រាជធានី ខេត្ត និងការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ គប្បីបញ្ចូលក្នុងផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួន ដែលជាផ្នែកមួយនៃថវិកាកញ្ចប់សេវាសង្គម សម្រាប់ការអនុវត្តសកម្មភាពចុះអធិការកិច្ចកន្លែងថែទាំកុមារទាំងអស់ជាទៀងទាត់។ ធ្វើការគ្រប់គ្រងករណីកុមារតាមរយៈប្រព័ន្ធ Primero ដើម្បីទប់ស្កាត់ករណីយកកុមារចូលក្នុងមណ្ឌលថែទាំ និងករណីសមាហរណកម្មកុមារ និងថវិកាសម្រាប់ទិញឧបករណ៍កំព្យូទ័រ ឬថេបប្លេត (tablet) សេវាថែទាំ/ជួសជុលឧបករណ៍ទាំងនោះ
- បញ្ចូលក្នុងផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួនសម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធអធិការកិច្ច និងការចុះផ្តល់បច្ចេកទេសនិងតាមដានត្រួតពិនិត្យ ការវិភាគទិន្នន័យ និងការរៀបចំរបាយការណ៍ ការបណ្តុះបណ្តាល ដល់មន្ត្រី មន្ទីរ ស.អ.យ រាជធានី ខេត្ត និងការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ ដើម្បីអនុវត្តបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារឱ្យមានប្រសិទ្ធិភាពខ្ពស់

- ពង្រឹងវិធានការត្រួតពិនិត្យកន្លែងថែទាំកុមារ ដូចខាងក្រោម៖
    - ចេញលិខិតជូនដំណឹងផ្លូវការជាប្រចាំទៅដល់កន្លែងថែទាំកុមារ ដែលមិនអនុវត្តស្របតាមបទដ្ឋាន និងស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ។ លិខិតនេះគប្បីផ្តល់នូវអនុសាសន៍ជាក់លាក់សម្រាប់ការកែលម្អ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គប្បីស្នើឱ្យកន្លែងថែទាំកុមារ ផ្តល់ផែនការសកម្មភាពរបស់ពួកគេក្នុងការដោះស្រាយអនុសាសន៍ទាំងនេះ
    - ដាក់បញ្ចូលគោលនយោបាយកិច្ចការពារកុមារ និងសុវត្ថិភាពកុមារ ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាទៅក្នុងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារថ្មីដែលកំពុងស្ថិតក្នុងដំណើរការរៀបចំ
    - បន្ថែមលើអធិការកិច្ចជាទៀងទាត់ អនុវត្តអធិការកិច្ចពិសេសជាក់លាក់ទៅលើកន្លែងថែទាំកុមារ ដើម្បីតាមដានលើការអនុវត្តអនុសាសន៍ និងឆ្លើយតបចំពោះកន្លែងថែទាំកុមារ ដែលមានហានិភ័យខ្ពស់
    - ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គប្បីពង្រឹងការប្រមូល ការវិភាគ និងការប្រើប្រាស់ទិន្នន័យពីអធិការកិច្ច សម្រាប់ការរៀបចំកម្មវិធី និងការវិភាជថវិការដ្ឋាភិបាល។
- ពង្រឹងសមត្ថភាពរបស់បុគ្គលិកសង្គម និងអ្នកថែទាំកុមារនៅក្នុងកន្លែងថែទាំ ដែលមានកុមារមានពិការភាពរស់នៅច្រើន តាមរយៈការរៀបចំមេរៀន "ការរួមបញ្ចូលជនមានពិការភាព" (Disability Inclusion) និងវិធីសាស្ត្រធ្វើការជាមួយជនមានពិការភាព ក្នុងកម្មវិធីសិក្សាជាស្តង់ដានៅវិទ្យាស្ថានជាតិសង្គមកិច្ច
- បើកវគ្គបណ្តុះបណ្តាលតាមសេចក្តីត្រូវការ និងវគ្គបណ្តុះបណ្តាលជាក់លាក់ដែលអនុវត្តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គប្បីបន្ត ដោយរៀបចំទៅតាមសេចក្តីត្រូវការរបស់បុគ្គលិកសង្គម និងអ្នកថែទាំកុមារនៅក្នុងកន្លែងថែទាំ
- សហការជាមួយដៃគូរពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលគោលការណ៍ណែនាំសមរម្យសម្រាប់ជនមានពិការភាព របស់អង្គការសហប្រជាជាតិ ទៅក្នុងនីតិវិធីអនុវត្តស្តីពីគោលនយោបាយថែទាំជំនួសចំពោះកុមារ
- រៀបចំគោលការណ៍ណែនាំអំពីការធ្វើអធិការកិច្ចកន្លែងថែទាំកុមារ និងទម្រង់អធិការកិច្ច ស្របតាមបទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារថ្មី និងបញ្ចូលគោលការណ៍ណែនាំសមរម្យសម្រាប់ជនមានពិការភាពទៅក្នុងឯកសារទាំងនោះ
- ធ្វើបច្ចុប្បន្នភាពប្រភេទពិការភាព នៅក្នុងគោលការណ៍ណែនាំអំពីការធ្វើអធិការកិច្ច និងទម្រង់អធិការកិច្ចកន្លែងថែទាំកុមារ ដើម្បីឱ្យការកំណត់ពិការភាពនៃកុមាររស់នៅក្នុងកន្លែងថែទាំ ស្របទៅតាមគោលការណ៍ណែនាំអំពីការកំណត់អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន។

## ២. រដ្ឋបាលថ្នាក់ក្រោមជាតិ

### ក. រដ្ឋបាលរាជធានី ខេត្ត

- ពង្រឹងការពិនិត្យ និងសម្រេចលើសំណុំឯកសារដែលសុំបញ្ចូល បញ្ចេញកុមាររងគ្រោះនិងងាយរងគ្រោះនៅក្នុងមណ្ឌលរបស់រដ្ឋ
- ពង្រឹងការគ្រប់គ្រងករណីនៅក្នុងមណ្ឌល ធ្វើសមាហរណកម្ម បង្រួបបង្រួមគ្រួសារ ការតាមដាន និងការបិទករណីរបស់កុមារ ជាពិសេសកុមារដែលមានពិការភាព
- បណ្តុះបណ្តាលបំណិនជីវិត និងជំនាញវិជ្ជាជីវៈសម្រាប់កុមារមានអាយុច្រើនដែលមិនអាចរកគ្រួសារអចិន្ត្រៃយ៍បានមុនពេលពួកគេឈានដល់ភាពពេញវ័យ

- រៀបចំបញ្ជីបច្ចុប្បន្នភាពកុមារនៅក្នុងមណ្ឌលរដ្ឋ និងសំណុំឯកសារដែលត្រូវស្នើបញ្ជូនមកក្រសួង ស.អ.យ
- ពង្រឹងកិច្ចសហការជាមួយកន្លែងថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងបុគ្គលិកថ្នាក់ក្រុង ស្រុក ខណ្ឌ និងអាជ្ញាធរឃុំ សង្កាត់ ដើម្បីធានានូវការធ្វើសមាហរណកម្មកុមារ ជាពិសេសកុមារមានពិការភាព ប្រកបដោយប្រសិទ្ធភាពទៅកាន់គ្រួសារវិញ តាមរយៈការគ្រប់គ្រងករណីកុមារតាមប្រព័ន្ធ Primero និងស្របតាមនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

### ខ. រដ្ឋបាលក្រុង ស្រុក ខណ្ឌ

- វិភាជថវិកាដល់ការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ សម្រាប់អនុវត្តមុខងារដូចបានកំណត់នៅក្នុងអនុក្រឹត្យលេខ៣៤ ស្ដីពីការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសការចុះធ្វើអធិការកិច្ចកន្លែងថែទាំកុមារ ទិញឧបករណ៍កំព្យូទ័រ ឬផេបប្លេត (tablet) សេវាថែទាំ/ជួសជុល
- ពង្រឹងការគ្រប់គ្រងករណីកុមារដោយប្រើប្រាស់ប្រព័ន្ធ Primero ដើម្បីទប់ស្កាត់ករណីយកកុមារចូលក្នុងមណ្ឌលថែទាំ និងករណីសមាហរណកម្មកុមារ
- ពង្រឹងការត្រួតពិនិត្យនិងសម្រេចលើសំណុំឯកសារដែលសុំបញ្ចូល ឬបញ្ចេញកុមាររងគ្រោះ និងងាយរងគ្រោះសម្រាប់មណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល
- ពង្រឹងការតាមដានការបញ្ជូនករណីកុមារ និងការផ្ដល់សេវាសុខុមាលភាពកុមារនៅក្នុងមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល។

### គ. រដ្ឋបាល ឃុំ សង្កាត់

